# មើលឆ្នាំជាធាតុ

| | | |
|---|---|---|
| ឆ្នាំជូត ធាតុទឹក | ឆ្នាំឆ្លូវ ធាតុដី | ឆ្នាំខាល ធាតុឈើ |
| ឆ្នាំកុរ ធាតុទឹក | ឆ្នាំច ធាតុដី | ឆ្នាំថោះ ធាតុឈើ |
| ឆ្នាំរោង ធាតុមាស | ឆ្នាំម្សាញ់ ធាតុភ្លើង | ឆ្នាំវក ធាតុដែក |
| ឆ្នាំមមែ ធាតុមាស | ឆ្នាំមមី ធាតុភ្លើង | ឆ្នាំរកា ធាតុដែក |

......................................

## មើលពង្ស

| | | |
|---|---|---|
| ឆ្នាំជូត ទេព្តាប្រុស | ឆ្នាំឆ្លូវ មនុស្សប្រុស | ឆ្នាំខាល យក្ខស្រី |
| ឆ្នាំរោង ទេព្តាប្រុស | ឆ្នាំម្សាញ់ មនុស្សប្រុស | ឆ្នាំច យក្ខស្រី |
| ឆ្នាំថោះ មនុស្សស្រី | ឆ្នាំមមី ទេព្តាស្រី | ឆ្នាំវក យក្ខប្រុស |
| ឆ្នាំកុរ មនុស្សស្រី | ឆ្នាំមមែ ទេព្តាស្រី | ឆ្នាំរកា យក្ខប្រុស |

..........................................

## មើលសញ្ជាតិ

| | | |
|---|---|---|
| ឆ្នាំជូត កណ្តុរ | ឆ្នាំរោង នាគរាជ | ឆ្នាំវក ស្វា |
| ឆ្នាំឆ្លូវ គោ | ឆ្នាំម្សាញ់ ពស់វែក | ឆ្នាំរកា មាន់ |
| ឆ្នាំខាល ខ្លា | ឆ្នាំមមី សេះ | ឆ្នាំច ឆ្កែ |
| ឆ្នាំថោះ ទន្សាយ | ឆ្នាំមមែ ពពែ | ឆ្នាំកុរ ជ្រូក |

..............................................

## មើលចងសម្ពង្សថ្ងៃ

ប្រុស និងស្រី កាលណាបានគ្នាជាប្តី-ប្រពន្ធ ភ័ព្វល្អត្រូវសម្ពង្សថ្ងៃកំណើតគ្នា ជាគុណប្រយោជន៍បានជាមិត្តមានចិត្តមេត្រីប្រណីដល់គ្នានិងគ្នា ជាទីស្និទ្ធគ្រងគ្នាក្នុងសមភាព និងភាតរភាព ។

អ្នកកើតថ្ងៃអាទិត្យ បានគូគ្រងកើតថ្ងៃព្រហស្បតិ៍ ជាមិត្តអ្នកកើតថ្ងៃអាទិត្យ បានគូគ្រងកើតថ្ងៃអង្គារ ជាសត្រូវ និងគ្នា ។

អ្នកកើតថ្ងៃចន្ទ បានគូគ្រងកើតថ្ងៃពុធ ជាមិត្តនិងគ្នា អ្នកកើតថ្ងៃចន្ទ បានគូគ្រងកើតថ្ងៃព្រហស្បតិ៍ ជាគូនិងគ្នា

អ្នកកើតថ្ងៃអង្គារ បានគូគ្រងកើតថ្ងៃសុក្រ ជាមិត្តនិងគ្នា អ្នកកើតថ្ងៃអង្គារ បានគូគ្រងកើតថ្ងៃព្រហស្បតិ៍ ជា សត្រូវនិងគ្នា ។

អ្នកកើតថ្ងៃពុធ បានគូគ្រងកើតថ្ងៃសៅរ៍ សត្រូវបន្តិចបន្តួច ។

អ្នកកើតថ្ងៃព្រហស្បតិ៍ បានគូគ្រងកើតថ្ងៃសុក្រ ជាមិត្តនិងគ្នា អ្នកកើតថ្ងៃព្រហស្បតិ៍ បានគូគ្រងកើតថ្ងៃចន្ទ ជា សត្រូវនិងគ្នា ។

អ្នកកើតថ្ងៃសុក្រ បានគូគ្រងកើតថ្ងៃអង្គារ ជាមិត្តនិងគ្នា អ្នកកើតថ្ងៃសុក្រ បានគូគ្រងអ្នកកើតថ្ងៃចន្ទ ជាសត្រូវ និងគ្នា ។

អ្នកកើតថ្ងៃសៅរ៍ បានគូគ្រងកើតថ្ងៃរាហ៊ូ ជាមិត្តនិងគ្នា  អ្នកកើតថ្ងៃសៅរ៍ បានគូគ្រងកើតថ្ងៃព្រហស្បតិ៍ ជា សត្រូវនិងគ្នា ។

អធិប្បាយ : តាមការណែនាំរបស់អាចារ្យខ្លះពោលថា អាការយកគូគ្រងរួមកំណើតថ្ងៃជាមិត្តនិងគ្នា ច្រើនមានចិត្តអធ្យាស្រ័យស្របគ្នាហួសពេក ជាហេតុឱ្យបានទទួលសេចក្ដីលំបាកក្នុងការគ្រប់គ្រងរក្សាសម្បត្តិ ព្រោះតែចិត្តស្រុះស្រួលមូលមតិគ្នាហួស កាលល្អក៏ស្មើគ្នា លុះអាក្រក់ក៏អាក្រក់ប្រហែលគ្នា ។

ការណែនាំរបស់អាចារ្យខ្លះពោលថា បើត្រូវគ្នាស្របស្រួលគ្នាជាការល្អជាងអាការខុសគ្នា គឺថាមិនខ្វែងយោបល់គ្នាមិនទទឹងរឹងមានៈប្រកួតប្រកាន់គ្នា យ៉ាងនេះឈ្មោះថាបានសុខបានប្រសើរ ។

តាមការពិសោធន៍ មិតនៅរួម គឺគ្រួសារជាមិត្ត បានផលល្អគ្រប់រយៈ ដូចជាកាងារប្រចាំគ្រួសារ ចេះជួយគ្នាដោយ ស្ម័គ្រស្មោះរីឯសត្រូវជារួមវិញ ចេញទើសចូលទើស ដូចពស់ក្បាលច្រើន លំបាកក្នុងការចូលរូង ឬចេញពីរូង ច្រងែងច្រង៉ាង ជាប់ជានិច្ច ។

.........................................

## មើលសម្ពង្សខែកើត

ន័យនេះ ពោលគឺការជ្រើសរើសរកសម្ពង្សខែកើតរវាងបុរសនិងស្ត្រី ដែលមានភារកិច្ចល្អ ចងសម្ព័ន្ធស្ដីសណ្ដឹងយកគ្នាប្រចាំគូជីវិតដើម្បីជោគសួស្ដីរួម បើត្រូវជ្រើសរកឱ្យត្រូវលក្ខណៈជតា ចូរសង្កេតពិនិត្យមើលកំណើតខែរៀងខ្លួនកាលណាបានត្រូវលក្ខណៈស្របគ្នា ឬមិនស្របគ្នា សូមពិចារណាដូចតទៅនេះ :

អ្នកកើតខែ "មេសា" យកគ្នាអ្នកកើតខែ "កុម្ភៈ"បានជាមិត្ត នៅរួមសុខទុក្ខនិងគ្នាបានប្រសើរ មានវឌ្ឍនៈភាព ណាស់បើបានលើអ្នកកើតខែ"តុលា"ជាសត្រូវនិងគ្នា ច្រើនមានហាយន ភាពក្រៅពីខែដូចពោលនេះ ជាមធ្យមទាំងអស់ ។

អ្នកកើតខែ "ឧសភា"យកគ្នានិងអ្នកកើតខែ"វិច្ឆិកា"បានជាមិត្តនៅរួមសុខទុក្ខនិងគ្នាបានប្រសើរ មានវឌ្ឍនៈភាព ល្អបើយកអ្នកកើតខែ"ធ្នូ"ជាសត្រូវនិងគ្នា ច្រើនបានហាយនៈភាព ក្រៅពីខែទាំងពីរនេះ ជាមធ្យមទាំងអស់ ។

អ្នកកើតខែ "មិថុនា" យកអ្នកកើតខែ"សីហា"បានជាមិត្តនិងគ្នា នៅរួមសុខទុក្ខនិងគ្នាបានប្រសើរ មានវឌ្ឍនភាពបើយកអ្នកកើតខែ"មករា"ជាសត្រូវនិងគ្នា ច្រើនបានហាយនភាព ក្រៅពីខែទាំង២នេះ ជាមធ្យមទាំងអស់ ។

អ្នកកើតខែ"កក្កដា"យកអ្នកកើតខែ"មីនា"បានជាមិត្តនិងគ្នា ដោយរួមសុខទុក្ខបានប្រសើរ មានវឌ្ឍនភាពល្អ បើយកអ្នកកើតខែ"កុម្ភៈ"ជាសត្រូវនិងគ្នា ច្រើនបានហាយនភាព ក្រៅពីខែទាំង២នេះ ជាមធ្យមទាំងអស់ ។

អ្នកកើតខែ"កញ្ញា"យកអ្នកកើតខែ"តុលា"បានជាមិត្តនិងគ្នា នៅរួមសុខទុក្ខបានប្រសើរ មានវឌ្ឍនភាពល្អ បើយកអ្នកកើតខែ"មីនា"ជាសត្រូវនិងគ្នា ច្រើនបានហាយនភាព ក្រៅពីខែទាំង២នេះ ជាមធ្យមទាំងអស់ ។

អធិប្បាយ : អាការយកខែត្រូវជាមិត្តនិងគ្នាមានគុណប្រយោជន៏វែងឆ្ងាយជាងថ្ងៃជាមិត្ត ។ ឧទាហរណ៏នាយ"ក"កើតថ្ងៃព្រហស្បតិ៍ ខែសីហា គាត់ដណ្ដឹងនាង "ខ"កើតថ្ងៃសៅរ៍ ខែមីថុនា , ព្រហស្បតិ៍ និង សៅរ៍ ជាសត្រូវនិងគ្នា ស្មោះតែខែមិថុនានិងសីហា ត្រូវជាមិត្តនិងគ្នា លុះនាយបាននាងជាស្វាមីភរិយានៅរួមរស់ជាមួយគ្នា ជីវភាពអ្នកទាំង២ប្រព្រឹត្តទៅបានជាមធ្យម ក្នុងរវាង១៥ឆ្នាំ តែក្នុងរយៈនេះច្រើនមានការតបតពាក្យសម្ដីគ្នាជាញឹកញាប់ មិនសូវចុះសម្រុងចូលធ្លុងគ្នាតែពាក្យសម្ដីចំពោះចិត្តអធ្យាស្រ័យស្រឡាញ់តាមធម្មតា ហើយរក្សាគ្នាតាមសភាពសមគួរ គ្រាតែមានកូនប្រុស

ស្រីចូលធ្វើរាជការកាន់មុខតំណែងខ្ពស់ ទទួលខុសត្រូវផ្ទាល់ខ្លួន ដូច្នេះឃើញថា បើរកបានថ្ងៃក៏ជាមិត្ត ខែជាមិត្តថែមទៀត យ៉ាងនេះប្រពៃណាស់ ។

.......................................

## មើលសម្ពង្សធាតុ

អស់លោកអ្នកនាង មុននឹងផ្សំ ឬប្រគល់វាសនាឱ្យដល់គ្នានិងគ្នា យកធ្វើជាស្វាមីភរិយានោះ គប្បីវិនិច្ឆ័យរឿងនេះឱ្យបានសព្វគ្រប់បន្តិច ដោយហេតុថា ការយកធ្វើជាគូគ្រងមិនមែនយករាប់តែថ្ងៃទេ គឺប្រាកដជាយកវាលអាយុតែម្តង ដូចគតិពេចន៍ថា "ធ្វើស្រែខុសត្រូវ១ឆ្នាំ យកប្តី-ប្រពន្ធខុសចំណាំខុសវាល់អាយុ" បានន័យថា មិនងាយនិងបោះបង់ចោលគ្នាចាប់ដៃដោយមានកូនពូនជចៅជុំវិញខ្លួនទៅហើយ ម្តេចក៏ស៊ូទ្រាំខុសធារ១ជាតិចោលទៅចុះ ទ្រាំលេបគ្រួសលេបថ្មជាជវាប ទៅ ។

ដូច្នេះគប្បីសង្កេតនូវលក្ខណៈកំណើតដូចតទៅនេះ :

បើប្រុសជាធាតុទឹក ស្រីក៏ធាតុទឹកដែរ នៅរួមរស់ជាមួយគ្នាបានសុខ មានសេចក្តីត្រជាក់ត្រជុំ សុខកាយសប្បាយ ចិត្ត ។

ប្រុសធាតុទឹក ស្រីធាតុដី សុខកាយសប្បាយចិត្តសុខល្អ រក្សាគ្នាបានយឺនយូរ ដីទ្រទ្រង់ទឹកឱ្យដក់ជាប់នៅ ។

ប្រុសធាតុទឹក ស្រីធាតុឈើ នៅរួមរស់ជាមួយគ្នាមានវឌ្ឍនភាពទៅដោយភោគសម្បត្តិ លូតលាស់ល្អ ។

ប្រុសធាតុទឹក ស្រីធាតុភ្លើង បានបន្ទាប់បន្សំដែរ តែមានហិងជាម្ចាស់ផ្ទះ ច្រើនដុតរោលឱ្យពុះរឿយ។ ។

ប្រុសធាតុទឹក ស្រីធាតុដែក នៅរស់ជាមួយគ្នាបានសេចក្តីរុងរឿង ថ្កុំថ្កើងឡើងយសសក្តិ ដែលមានស្នេហភាព ។

ប្រុសធាតុដី ស្រីធាតុដី នៅរួមរស់ជាមួយគ្នាបានជាកូនពូនជាចៅ រក្សាគ្នាបានសុខសាន្ត អាយុយឺនយូរ ។

ប្រុសធាតុដី ស្រីធាតុទឹក នៅរួមរស់ជាមួយគ្នាកន្លងបាន១ឆ្នាំឡើងទៅទើបបានល្អ មានគេឧបត្ថម្ភគម្ការជួយឈឺ ឆ្អាល ។

ប្រុសធាតុដី ស្រីធាតុឈើ នៅរួមរស់ជាមួយគ្នាមិនសូវបានល្អ ព្រោះដីមានគុណភាពធ្ងន់ ច្រើនទម្រន់មើលបំណាំ។

ប្រុសធាតុដី ស្រីធាតុភ្លើង នៅរួមរស់ជាមួយគ្នាបានទុក្ខលំបាកពីដំបូងដៃ លុះដល់ចុងដៃទើបសម្បូរដោយទ្រព្យ ។

ប្រុសធាតុដី ស្រីធាតុដែក នៅរួមរស់ជាមួយគ្នាបានកូន៧នាក់ ដែកមានគុណភាពរឹងមុត តែរិលទៅដោយដី ។

ប្រុសធាតុឈើ ស្រីធាតុឈើ នៅរួមរស់ជាមួយគ្នាមិនសូវល្អ មិនលូតលាស់ដុះដាលលាភផលឡើយ គ្មានអ្នក ទ្រទ្រង់គ្នា ។

ប្រុសធាតុឈើ ស្រីធាតុទឹក នៅរួមរស់ជាមួយគ្នាប្រសើរណាស់ សំបូរធនធាន តែចិញ្ចឹមកូនដោយកម្រណាស់ ។

ប្រុសធាតុឈើ ស្រីធាតុដី នៅរួមរស់ជាមួយគ្នាមានសេចក្តីស្រឡាញ់គ្នាណាស់ តែច្រើនឃ្លាតចាកគ្នាជារឿយ។។

ប្រុសធាតុឈើ ស្រីធាតុភ្លើង នៅរួមរស់ជាមួយគ្នាល្អ បើបានកូនប្រុសមុនជាទីពឹង តែច្រើនជាមនុស្សកំព្រា ។

ប្រុសធាតុឈើ ស្រីធាតុដែក នៅរួមរស់ជាមួយគ្នាមិនសូវបានយឺនយូរឡើយ ព្រោះគុណភាពដែកគ្របសង្កត់ ឬ ផ្តាច់ឈើ ។

ប្រុសធាតុភ្លើង ស្រីធាតុភ្លើង នៅរួមរស់ជាមួយគ្នាច្រើនអភ័ព្វ មានការតឹងថប់ក្តៅក្រហាយចិត្តច្រើន ឬចង្អៀត ចិត្តណាស់ ។

ប្រុសធាតុភ្លើង ស្រីធាតុទឹក នៅរួមរស់ជាមួយគ្នាកាលដំបូងមិនសូវល្អទេ លុះដល់ចាស់បន្តិចទើបល្អ តែឧស្សាហ៍ លាន់មាត់ ។
ប្រុសធាតុភ្លើង ស្រីធាតុឈើ នៅរួមរស់ជាមួយគ្នាមិនសូវល្អ រកទ្រព្យសម្បត្តិមិនបាន គុណភាពភ្លើងក្តៅឆេះរោល រាលណាស់ ។
ប្រុសធាតុភ្លើង ស្រីធាតុដែក នៅរួមរស់ជាមួយគ្នាមិនល្អ ច្រើនក្រខ្សត់ មានការក្តៅងំនៅក្នុងចិត្តថ្លើមរឿយ។ ឆេះ លាភផល ។

ប្រុសធាតុដែក ស្រីធាតុដែក នៅរួមរស់ជាមួយគ្នាបានសុខសាន្ត គុណភាពអាចចង់បានគ្នាកើតមានទ្រព្យ ។

ប្រុសធាតុដែក ស្រីធាតុទឹក នៅរួមរស់ជាមួយគ្នាបានប្រសើរណាស់ជាសុខ គុណភាពដែកមុត ឬទន់បាន ព្រោះទឹក

ប្រុសធាតុដែក ស្រីធាតុដី នៅរួមរស់ជាមួយគ្នាបានល្អណាស់ សំបូរទ្រព្យធន មានសម្បត្តិច្រើន ។

ប្រុសធាតុដែក ស្រីធាតុឈើ នៅរួមរស់ជាមួយគ្នាបានសេចក្តីសុខ មានយសបរិពារ រុងរឿងទៅដោយអំណាច ។

ប្រុសធាតុដែក ស្រីធាតុភ្លើង នៅរួមរស់ជាមួយគ្នាមិនល្អទេ ច្រើនបង្ករឿងឈ្លោះឈ្លានពានដាក់គ្នារឿយៗ ។

រីអ្នកធាតុមាស មិនបានរើសអើងរកធាតុមកផ្សំឡើយ ទោះផ្សំចូលជាមួយធាតុអ្វីក៏គួរសមទាំងអស់ មាសមានគុណភាពខ្ពស់ ហើយមិនមានហេតុជំទាស់និងធាតុណាផង ។

អធិប្បាយ : ធាតុទាំង៦សូមជ្រាបថា បុរាណជ្រើសយកធាតុខាងប្រុសមិនឱ្យទន់ខ្សោយជាងស្រីឡើយ ដោយសំ អាងថា កាលណាមានស្រីមានគុណភាពរឹង ឬមុតក្តៅជាងប្រុស ជាហេតុនាំមកដោយមហន្តរាយបានងាយជាទីបំផុត ។ ឧទាហរណ៍ នាយ ខ កើតឆ្នាំវក ធាតុដែកទៅចងសម្ព័ន្ធស្ដីដណ្តឹងនាង គ កើតឆ្នាំមមី ធាតុភ្លើង ភាពថ្លឹងទឹកទម្ងន់ទាំង២នេះ ឃើញថា ដែកចាញ់ឥទ្ធិពលភ្លើង ប្រាសចាកគុណភាពប្រក្រតី រក្សាតម្លៃដើមមិនបានគង់វង្ស ដូច្នេះគប្បីជ្រើសរើសធាតុប្រុសឱ្យមានគុណភាពធ្ងន់ ដើម្បីជាគុណប្រយោជន៍ចម្រើនផលឱ្យស្រី ។ នាង គ ហេតុតែនាងជាធាតុភ្លើង ចេះតែដុតរោល នាយ ខ ជានិច្ចកាល លុះច្រើនដងច្រើនគ្រាពេក នាយ ខ ក៏បាក់ស្បាត ខ្លាចនាង គ ទើបនាយហ៊ានធ្វើអំពើផ្ដេសផ្ដាស អនា ចារ ដើម្បីប្រមូលផលច្រើនយកមកផ្គាប់ចិត្តនាង គ កុំឱ្យដុតរោលដល់ខ្លួនគាត់ យ៉ាងនេះឯង ទើបបានជាតម្រូវឱ្យជ្រើសយកធាតុប្រុសមានគុណភាពខ្ពស់ជាងស្រី ដើម្បីហ៊ឹកហ៊ឺនស្រី និងរិតខ្សែឡើតឱ្យត្រង់ផ្លូវល្អ ហើយគ្រប់គ្រងគ្នាក្នុងផ្លូវសាមគ្គីរស់ តែម្យ៉ាង ។

..........................................

## មើលសម្ពង្សជាតិ

កាលមុននឹងសម្រេចភារៈរៀបអាពាហ៍ពិពាហ៍ប្រុសនិងស្រីឱ្យបានជាស្វាមី-ភរិយា ដើម្បីគ្រប់គ្រងគ្នាជាស្ថាពរ ប្រកបដោយគុណប្រយោជន៍ បានសេចក្តីសុខសំបូរនោះ គប្បីជ្រើសផ្សំពង្សជាតិឱ្យបានសមគួរដល់លក្ខណៈកំណើតទាំងសង ខាងដូចតទៅនេះ :

ទេព្ដាប្រុស និង ទេព្ដាស្រី នៅរួមរស់ជាមួយគ្នាល្អណាស់ មានកូនជាទីស្រឡាញ់ សម្បត្តិទ្រព្យជាមធ្យម ។

ទេព្ដាប្រុស និងមនុស្សស្រី នៅរួមរស់ជាមួយគ្នាជាមធ្យម កាលណាបានកូនម្នាក់ហើយ តទៅច្រើនជជែកប្រកែក គ្នា បើព្រាត់គ្នាម្តងហើយមកជួបគ្នាវិញនោះ ទើបបានល្អនៅជាសុខជាមួយគ្នា "ដូចព្រះរាម និងនាង សិតា" ។

មនុស្សប្រុស និងទេព្ដាស្រី នៅរួមរស់ជាមួយគ្នាល្អ បានកូនកាលមុនមានសេចក្តីស្រឡាញ់គ្នាណាស់ លុះក្រោយមកមានហេតុព្រាត់គ្នា ហើយបានជួបគ្នាវិញ នៅបានសុខសាន្តដរាបដល់អវសាន "ដូចព្រះនាង សុទ្ធត្ត និង នាងមនោរា" ។

ទេព្ដាប្រុស និងយក្សស្រី នៅរួមរស់ជាមួយគ្នាជាមធ្យម មានបុត្រប្រុស-ស្រីច្រើនឈ្លោះឆ្លើយគ្នាញឹក ។

មនុស្សប្រុស និង យក្សស្រី នៅរួមរស់ជាមួយគ្នាស្រឡាញ់គ្នាតែដំបូង លុះយូរទៅនឹងមានហេតុត្រូវឃ្លាតគ្នារហូត "ដូចពុទ្ធិសែន និង នាងកង្រី" ។

មនុស្សប្រុស និង មនុស្សស្រី នៅរួមរស់ជាមួយគ្នាបានសុខសាន្ត មានជន្មាយឺនយូរ មានបុត្រធីតាល្អ ប្រកបកិច្ចការអាជីវកម្មកើនផលបរិបូរណ៍ មានសេចក្តីសាមគ្គីស្នេហ៍ចិត្តគ្នា "ជាមហាឧត្តម" ។

យក្សប្រុស និង មនុស្សស្រី នៅរួមរស់ជាមួយគ្នាមិនល្អទេ មានកូនកាលនៅរួមគ្នា ស្រឡាញ់តែកំពុងថ្មោងថ្មី លុះយូរទៅនឹងបណ្តាលហេតុឱ្យព្រាត់ចាកគ្នា "ដូចយក្សកុម្ភណ្ឌ និងនាង កែវសុមន្ទា" ។

យក្សប្រុស និង យក្សស្រី នៅរួមរស់ជាមួយគ្នាបានល្អ មានបុត្រធីតាមធ្យម តែច្រើនលាន់មាត់ដាក់គ្នា ទឹកចិត្ត ខ្លាំងដូចគ្នា (ច្រើនបន្ទុះគ្នាទៅវិញទៅមក) ។

........................................................